

# ឈានដល់កម្រិតថ្មី

# សន្និសីទកំពូលស្តីពីមីក្រូហិរញ្ញវត្ថុ ឆ្នាំ ២០០៧

## *លទ្ធភាពទទួលសេវាកម្មហិរញ្ញវត្ថុកាន់តែប្រសើរឡើង*

## *បទបង្ហាញរបស់វិនិយោគិន*

ថ្ងៃទី ៣០ ខែ វិច្ឆិកា ២០០៧

GRET

# តើយើងគឺជាអ្នកណា?

- អង្គការក្រៅរដ្ឋាភិបានផ្នែកអភិវឌ្ឍន៍ ដែលមានទីតាំងនៅប្រទេសបារាំង បង្កើតឡើងនៅក្នុងឆ្នាំ ១៩៧៦
- អនុវត្តន៍គម្រោង / ជំនាញរយៈពេលខ្លី / គោលនយោបាយសាធារណៈ / ការគ្រប់គ្រងចំណេះដឹង
- បទពិសោធន៍ការងារនៅក្នុងប្រទេសកំពុងអភិវឌ្ឍជាង ៤0
- មានបុគ្គលិក ៩0 នាក់នៅប្រទេសបារាំងនិងបរទេស
- មាននាយកដ្ឋានតាមវិស័យចំនួន ៦
- នាយកដ្ឋានមីក្រូហិរញ្ញវត្ថុនិងសហគ្រាសធុនតូចទទួលបន្ទុកការងារមីក្រូហិរញ្ញវត្ថុ ការងារមីក្រូធានារ៉ាប់រង និង BDS
- www.gret.org ដើម្បីទទួលព័ត៌មានបន្ថែមទៀតអំពីយើង



# ហេតុអ្វីបានជាវិនិយោគលើ អម្រិត?

- Gret បានចាប់ផ្តើមសកម្មភាពមីក្រូហិរញ្ញវត្ថុនៅកម្ពុជាក្នុងឆ្នាំ ១៩៩២
- ចុងទសវត្សរ៍ ១៩៩0 = ដំណាក់កាលកែប្រែ
  - ជម្រើសឋានៈផ្លូវការដែលស្របគ្នានឹងល័ក្ខខ័ណ្ឌច្បាប់ និង អាជីវកម្មរបស់អម្រិត និង គម្រូស្ថាប័នក្រុមហ៊ុនទទួលខុសត្រូវ ➡ មានកម្រិត
  - Gret ចាំបាច់ត្រូវបង្ហាញការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះការអភិវឌ្ឍន៍អម្រិត សម្រាប់អ្នកផ្តល់ជំនួយ វិនិយោគិន អ្នកឱ្យខ្ចីប្រាក់ ធនាគារជាតិនៃកម្ពុជា ។ល។
  - Gret ចង់រក្សាតួនាទីចម្បងនៅក្នុងអភិបាលកិច្ចគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
    - ដើម្បីរក្សាចក្ខុវិស័យ/បេសកកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
    - ដើម្បីចូលរួមយ៉ាងសកម្មនៅក្នុងរៀបចំនិងការអនុវត្តយុទ្ធសាស្ត្រ
    - ដើម្បីអាចទទួលបាននូវការទទួលខុសត្រូវតាមកិច្ចសន្យារបស់ខ្លួនចំពោះអ្នកផ្តល់ជំនួយ (កិច្ចសន្យាជំនួយបច្ចេកទេស)
  - ធនាគារជាតិនៃកម្ពុជាបានឯកភាពផ្តល់ដិប្បញ្ញត្តិចំពោះការទទួលខុសត្រូវរបស់ម្ចាស់ភាគហ៊ុនមានឥទ្ធិពល
  - មិនសូវមានវិនិយោគិនច្រើនទេដែលវិនិយោគនៅពេលនោះ

GRET



# តើគោលដៅរបស់ Gret ជាវិនិយោគិនមួយត្រូវ បានសម្រេចឬទេ (តើប្រការនេះត្រូវបានវាស់ដូចម្តេច?)

- ពិតមែនហើយ:
  - អម្រិតបានរីកលូតលាស់ទន្ទឹមគ្នានឹងការរក្សាចក្ខុវិស័យ/បេសកកម្មរបស់ខ្លួនជាចំណុចរួមមួយសម្រាប់គ្រប់ភាគីពាក់ព័ន្ធទាំងអស់
  - អម្រិតបានរីកចម្រើនយ៉ាងលឿនដោយសារសមត្ថភាពរបស់អម្រិតក្នុងការទាក់ទាញអ្នកឱ្យប្រាក់ខ្ចីថ្មី និង វិនិយោគិនថ្មី
  - អម្រិតនៅមិនទាន់មានជួបប្រទះបញ្ហាអភិបាលកិច្ចទេមកដល់ពេលនេះ
  - បច្ចុប្បន្ននេះ វិនិយោគិនថ្មីចង់ចូលរួមជាមួយអម្រិត



## តើ Gret នឹងបន្តធ្វើជាវិនិយោគិនទុនក្រោយរយៈពេល ៥ ឆ្នាំ ឬទេ?
## តើ Gret នឹងបំពេញតួនាទីអ្វីក្នុងការអភិវឌ្ឍថែមទៀតនៃវិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ?

- Gret មានបំណងកាត់បន្ថយការចូលរួមរបស់ខ្លួននៅក្នុងទុនរបស់អម្រិតដល់ក្រោម ២0% - ដើម្បីជៀសវាងការទទួលខុសត្រូវជាម្ចាស់ភាគហ៊ុនមានអំណាច
- ពុំមានការិយបរិច្ឆេទនៃការចាកចេញទេ
- Gret នឹងស្ថិតនៅជាម្ចាស់ភាគហ៊ុនតូចសកម្ម - បំពេញតួនាទីដ៏សកម្មនៅក្នុងការរក្សាចក្ខុវិស័យ /បេសកកម្មរបស់អម្រិត និង ក្នុងការកំណត់យុទ្ធសាស្ត្ររបស់អម្រិត
- ការកែលម្អស្នាដៃសង្គមកិច្ចរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺជាចំណោទដ៏ធំមួយសម្រាប់ឧស្សាហកម្មមីក្រូហិរញ្ញវត្ថុ => Gret នឹងរួមចំណែកដល់ការជម្រុញសូចនាករស្នាដៃសង្គម និង នឹងជួយគាំទ្រគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដើម្បីកែលម្អស្នាដៃសង្គមរបស់ពួកគេ
- ប្រការនេះនឹងត្រូវបានធ្វើនៅកម្ពុជាប្រសិនបើសមស្រប



# ទស្សនៈអំពីវិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា

- មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំៗជាច្រើននៅកម្ពុជាបើប្រៀបធៀបទៅប្រទេសមួយចំនួនផ្សេងទៀត ជាពិសេសនៅតាមតំបន់ភូមិសាស្ត្រជាក់លាក់មួយចំនួន
- គ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់នឹងមិនអាចរក្សាបាននូវកំណើនខ្លាំង (លើ ៥០%) តាមផែនការបានទេ ទោះបីជាផលិតផលក្នុងស្រុកសរុបកម្ពុជានៅតែកើនឡើងក្តី
- ការចូលរួមគ្នាពិតជាគប្បីត្រូវពិចារណា
- ពិពិធកម្មផលិតផលគឺជាបញ្ហាប្រឈមដ៏ធំមួយ (ប្រាក់សន្សំ គ្រប់គ្រងសាច់ប្រាក់ ។ល។) ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអាចចាំបាច់ត្រូវប្រែក្លាយទៅជាធនាគារប្រសិនបើមិនត្រូវបានអនុញ្ញាតដោយបទបញ្ញត្តិឱ្យផ្តល់ផលិតផលផ្សេងទៀតឱ្យបានកាន់តែទូលាយ
- ប្រសិនបើឧស្សាហកម្មមីក្រូហិរញ្ញវត្ថុនៅកម្ពុជាចង់បង្កើនផលប៉ះពាល់របស់ខ្លួនលើកិច្ចអភិវឌ្ឍន៍ និងស្នាដៃសង្គមកិច្ចរបស់ខ្លួន ភាពជាដៃគូថ្មីជាមួយភាគីពាក់ព័ន្ធមិនមែនហិរញ្ញវត្ថុប្រហែលជាចាំបាច់ដើម្បីដោះស្រាយបញ្ហាថ្មីៗ (លទ្ធភាពទទួលបានការងារ ការអប់រំ សុខភាព ។ល។)